# ៨. ការគោរពអារក្សអ្នកតានិងការអភិរក្សព្រៃឈើនៅក្នុងអាងទន្លេមេគង្គ

## ១. ការគោរពអារក្សអ្នកតានិងព្រៃឈើ

នៅខេត្តយុនណានប្រទេសចិន ប្រទេសឡាវភាគឦសាននៃប្រទេសថៃភាគពាយ័ព្យរបស់ប្រទេសវៀតណាម គឺជាតំបន់អាងទន្លេមេគង្គ ជនជាតិដៃយយ៍(Dai)ហានី(Hani)ឡាវនិងក្រុមជនជាតិដើមភាគតិចដទៃទៀតនៅតែអនុវត្តពិធីបុណ្យសម្រាប់អារក្សដែលរស់នៅក្នុងព្រៃនិងមានដំណមជាច្រើនដែលគេគោរពតមករហូតដល់សព្វថ្ងៃនេះនៅពេលប្រើប្រាស់ព្រៃឈើ។ ការគោរពអារក្សបាននឹងកំពុងមានមុខងារជាការពិនិត្យនៅក្នុងការប្រើប្រាស់ព្រៃឈើ និងការកាប់ឈើហួសហេតុ។

| ក្រុមជនជាតិ | ទីតាំង | ការពិពណ៌នាអំពីពិធីបូជាអារក្ស | ប្រភព |
|---|---|---|---|
| ជនជតិហានី (អាខា នៅខាងជើងប្រទេសភូមា, ឡាវ និង ប្រទេសថៃ) | ប្រជាជន ហានី(Hani) រស់នៅក្នុងភាគខាងត្បូងខេត្តយុនណាន និង នៅតាមបណ្តោយព្រំដែនភាគខាងជើងនៃប្រទេសភូមា/ ប្រទេសមីយ៉ាន់ម៉ាឡាវ និងប្រទេសវៀតណាម | ប្រជាជនហានី(Hani)ជឿថាអារក្សនីមួយៗមានទីលំនៅផ្ទាល់ខ្លួន(ដូចជានៅតំបន់ដីសើម ស្រះទឹក ថ្ម ជាពិសេសដើមឈើ។ល។) អារក្ស ទាំងនេះបានរស់នៅក្នុងព្រៃឈើ។ នៅក្នុងព្រៃបែបនេះវាគឺជាតំបន់ដែលមាន ដំណមសំរាប់អ្នកភូមិហានី(Hani ) ក្នុងការយកទាញយកអនុផលព្រៃឈើ, ការបរបាញ់សត្វឬការកាប់រំលំដើមឈើជាដើម។ | Xu et al (2005) |
| ជនជាតិដាយយ៍ | ប្រជាជនដាយយ៍(Dai )ដែលរស់នៅក្នុងភាគពាយព្យប្រទេសវៀតណាមតំបន់ភ្នំនៃប្រទេសឡាវនៅភាគខាងកើតប្រទេសមីយ៉ាន់ម៉ា (ភូមា) ភាគខាងជើងប្រទេសថៃ និងភាគខាងត្បូងខេត្តយុនណាន។ | ប្រជាជនដាយយ៍(Dai)ជាប្រពៃណីពួកគេមានជំនឿថា អារក្ស និងជំនឿនៃសាសនាគឺពិតជាមាននៅក្នុងអំណាចធម្មជាតិ ដូចជាមាននៅក្នុងព្រៃឈើសត្វនិងរុក្ខជាតិនានា។ ការធ្វើឲ្យអោយអារក្សមានកំហឹងជាមួយនឹងឥរិយាបទមិនសមរម្យនាំមកនូវបាតុភូតធម្មជាតិជាច្រើនដែលបាននាំមកជាមួយនូវគ្រោះមហន្តរាយឬធ្វើឲ្យមានសំណាងដ៏អាក្រក់កើតមានដល់ភូមិនោះជាក់ជាមិនខាន។ ក្នុងចំណោមជនជាតិដាយយ៍ត្រូវបានលើកទឹកចិត្តឱ្យរស់នៅក្នុងភាពសុខដុមរមណីជាមួយបរិស្ថានធម្មជាតិដែលនៅជុំវិញខ្លួនពួកគេ។ | Xu et al (2005) |

| | | | |
|---|---|---|---|
| | ស្រុកដៀនបៀនដុង (Dien Bien Dong), នៅខេត្តឡៃឆូវ Lai Chau)របស់ប្រទេសវៀតណាម | ភូមិដាយយ៍(Dai)មានព្រៃឈើដ៏សក្តិសិទ្ធ ដែលជាទីកន្លែងនៃព្រលឹងដូនតារស់នៅនិងជាកន្លែងសំខាន់សំរាបការពារថែរក្សាដល់អ្នកភូមិ។ មនុស្សណាដែលបំពានលើព្រៃឈើដ៏សក្តិសិទ្ធនេះ អារក្សនឹងដកយកប្រលឹងអ្នកនោះ ហើយគេជឿថា អ្នកទាំងនោះអាចទៅជាឆ្កួតឬក៏ស្លាប់។ដើម្បីលាងកំហុសសម្រាប់អំពើបាប អ្នកមានកំហុសនោះត្រូវបានដាក់ធ្វើការទណ្ឌកម្ម ឬពិន័យដោយយោងទៅតាមក្បួនច្បាប់ក្នុងភូមិនិងត្រូវផាកពិន័យជាសត្វក្របីទឹក ឬសត្វពាហនៈដទៃទៀតដែលអាចបូជាបាន។ ម្យ៉ាងទៀតព្រៃដ៏សក្តិសិទ្ធទាំងនេះ ក៏ជាទ្រព្យសម្បត្តិរួមរបស់ភូមិផងដែរ ដូច្នេះពេលធនធានព្រៃឈើត្រូវបានលក់ចេញក្រៅ នោះប្រាក់ចំណូលគឺត្រូវបានដាក់បញ្ចូលទៅក្នុងមូលនិធិសហគមន៍រួមហើយត្រូវបានគ្រប់គ្រងចាត់ចែងយោងទៅតាមក្បួនច្បាប់ដាក់លាក់នៅក្នុងភូមិ។ | Tran (2007), |
| ជនជាតិឡាវ | នៅភាគឥព្សានប្រទេសថៃ | ក្នុងចំណោមក្រុមជនជាតិភាគតិចឡាវដែលរស់នៅភាគឥព្សាននៃប្រទេសថៃ ធ្វើការគោរពព្រៃឈើ ដែលហៅថាដុនភូតា(Don Phu Ta) ដែលក្នុងនោះត្រូវបានគេនិយាយទៅវិញ្ញាណរស់នៅផងដែរ។សូម្បីតែនៅភាគឥព្សាននៃប្រទេសថៃដែលជាកន្លែងមានការកាប់ព្រៃឈើច្រើនដុនភូតានៅតែមានសភាពល្អ ហើយតំបន់មួយចំនួននៃព្រៃឈើទាំងនោះបានក្លាយជាតំបន់អភិរក្សឬជាទ្រព្យសម្បត្តិរួមភូមិព្រមទាំងជាគោលដៅចំបងនៃកិច្ចខិតខំប្រឹងប្រែងអភិរក្ស។ | សំភាសន៍ដោយការឃ្លាំ Mekong Watch(2012) |

## ២. ព្រៃអារក្សនៃខេត្តសាវណ្ណាខេតនៃប្រទេសឡាវ

ព្រៃឈើមួយដែលគេហៅថា ដុន ណាថាតនុងលុម(Don NathatNongLom)នៅក្នុងភូមិតាអ៊ិនណាន(Thatoinhan)នៃស្រុកខាសុន(Kaisorn) (ជាផ្លូវការខាតតាបូរីKantaburi) នៃខេត្តការសាវណ្ណាខេតភាគកណ្ដាលប្រទេសឡាវត្រូវបានរក្សាទុកនៅក្នុងស្ថានភាពល្អ។ បើយោងទៅតាមការកត់ត្រារបស់ភូមិ ព្រៃនេះមានទំហំប្រហែល ៤.៣០០ហិចតាហើយក៏ជាប្រភពទឹកដ៏សំខាន់ក្នុងតំបន់។ ឥឡូវ វាត្រូវបានចាត់តាំងជាព្រៃអភិរក្សសាធារណៈ(ប៉ា សាគនPa Saguan)ប៉ុន្តែព្រៃនេះត្រូវបានគោរពជាទំលាប់ដោយអ្នកភូមិផងដែរដោយសារតែពួកគេជឿថាអារក្សដ៏ខ្លាំងរស់នៅទីនោះ។ ជំនឿទាំងនេះត្រូវគេប្រត្តិបត្តិតាមដល់សព្វថ្ងៃនេះនៅឡើយ ហើយនៅក្នុងខេត្តសាវណ្ណាខេត, ព្រៃឈើទាំងនេះត្រូវបានគេស្គាល់ថាជាព្រៃឈើ ម៉ាហាសែក (Mahasaek)។

មានភូមិមួយដែលមានប្រាសាទដ៏ល្បីហៅថា ថាត់ អ៊ីង-ហាន(That Ing-han) ។ ដំណមព្រៃឈើឥឡូវត្រូវបានពន្យល់ក្នុងន័យព្រះពុទ្ធសាសនា។ ព្រៃឈើមានព្រំប្រទល់នៅវាលភក់មួយដែលហៅថា ណុងលុម(NongLom)ប៉ុន្តែវាលភក់នេះត្រូវបានគេមើលដឹងផងដែរថាជាកម្មសិទ្ធិរបស់អារក្ស ហើយវាត្រូវបានហាមឃាត់សំរាប់ដឹកទូកចេញទៅរកត្រីឬទៅបរបាញ់សត្វព្រៃដែលព្រះពុទ្ធបានហាមមិនឱ្យបរិភោគ (ដូចជាពស់និងស្វាជាដើម ) ។

ជារៀងរាល់ឆ្នាំនៅខែមីនាពិធីបុណ្យសម្រាប់អារក្សត្រូវបានធ្វើឡើងដោយមិនមានសំណែនជាសាច់និងគ្រឿងស្រវឹងទេ។ មកដល់ថ្ងៃនេះអ្នកភូមិនៅតែជឿថាការទទួលយកអនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីអារក្ស ការកាប់ដើមឈើនិងការធ្វេសប្រហេសខកខានសែនគឺជាតំណម ហើយប្រសិនបើនរណាម្នាក់រំលោភច្បាប់ទាំងនេះត្រូវបានបានអារក្សបន្ទាចយ៉ាងខ្លាំងដល់អ្នកភូមិ អាចធ្លាក់ខ្លួនឈឺឬស្លាប់បាន។ វាត្រូវបាននិយាយថាអស់រយៈពេលជាច្រើនទសវត្សកន្លងទៅ ដោយសារតែពិធីបុណ្យពុទ្ធសាសនាបានក្លាយជាភាពសំខាន់ជាងនៅក្នុងភូមិ ចាស់ទុំភូមិបានបញ្ឈប់ធ្វើពិធីសែនព្រេនសម្រាប់អារក្ស។ បន្ទាប់មកនៅក្នុងពិធីព្រះពុទ្ធសាសនា ស្រាប់តែមានព្យុះដ៏ធំ បានបំផ្លិចបំផ្លាញតែភូមិមួយនេះប៉ុណ្ណោះដូច្នេះពួកគេដឹងថាពួកគេត្រូវបន្តធ្វើពិធីសែនព្រេនសម្រាប់អារក្ស។ គួរបញ្ជាក់ផងដែរថា ប្រសិនបើមាននរណាម្នាក់នៅក្នុងភូមិរំលោភតំណមនេះ គេនិយាយថាបាតុភូតចម្លែកត្រូវបានកើតឡើងដូចជាការមើលមិនឃើញសេះដែលកំពុងរត់នៅជុំវិញភូមិនៅពេលយប់។ ដូច្នេះប្រសិនបើគេស្គាល់ថានរណាម្នាក់បានបំពានតំណមទាំងនេះអ្នកភូមិពិភាក្សាគ្នាអំពីបញ្ហា ហើយធ្វើពិធីសែនព្រេនធ្វើឱ្យអារក្សស្ងប់ចិត្តក្នុងគោលបំណងដើម្បីការពារគ្រោះមហន្តរាយកើតមានដល់ភូមិ។

ខណៈពេលដែលអ្នកភូមិកាន់កាប់ព្រៃឈើនៅក្នុងសេចក្ដីស្ញើចពួកគេក៏បានប្រើវាជាមូលដ្ឋានរៀងរាល់ថ្ងៃ។ ការកាប់ដើមឈើគឺអាចធ្វើបានប្រសិនបើត្រូវបានទទួលការអនុញ្ញាត្តិ។ នេះបើយោងតាមមន្ត្រីភូមិប្រហែល ១០០គ្រួសារនៃ៣៦០គ្រួសារ របស់ភូមិ ថាតអ៊ីងហានដែលកំពុងប្រើធនធានព្រៃឈើនោះ ប៉ុន្តែគ្រួសារជាច្រើនដែលមកពី ១៣ភូមិដទៃទៀតនៅក្នុងតំបន់ជុំវិញក៏បានមកយកផលព្រៃឈើនូវអ្វីដែលពួកគេត្រូវការ។ នៅពេលវាជារដូវប្រមូលផលផ្សិតសូម្បីតែមនុស្សមកពីឆ្ងាយក៏មកដើម្បីប្រមូលផលផ្សិតដែរ។



ខ្ទមអារក្សនៅខេត្តស៊ីសាកេត ភាគខាងជើងប្រទេសថៃ

ក្នុងព្រៃនេះអ្នកភូមិប្រមូលផ្សិតណាដែលអាចបរិភោបបានស្មៅព្រៃទឹកឃ្មុំនិងជ័រទឹកដែលត្រូវបានប្រើជាឥន្ទនៈ។ ដោយសារតែវាទើបតែបានក្លាយជាព្រៃអភិរក្ស វាត្រូវបានហាមឃាត់ក្នុងការប្រមូលអុស។ ការពន្យល់ដែលបានផ្តល់ឱ្យនោះគឺថាមានការកើនឡើងចំនួនប្រជាជនដែលប្រមូលអុសមិនមែនសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេទេប៉ុន្តែសំរាប់លក់ដូច្នេះវាគឺជាវិធានការចាំបាច់ដើម្បីការពារព្រៃឈើ។

គួរបញ្ជាក់ផងដែរអនុផលព្រៃឈើគឺជាមធ្យោបាយនៃការស្វែងរកប្រាក់ចំណូលមួយ។ នៅក្នុងរដូវប្រាំងអ្នកភូមិប្រមូលជ័រទឹកមួយហៅថាណាមម៉ាណយ៉ាង(Nam ManYang)។ជ័រនេះត្រូវបានប្រើជាឥន្ទនៈសម្រាប់ធ្វើចន្លុះមានឈ្មោះថាកាបុង(kabong)។ អគ្គិសនីភាវូបនីយកម្មត្រូវបានរីករាលដាលនៅក្នុងប្រទេសឡាវដូច្នេះចន្លុះទាំងនេះមិនត្រូវបានប្រើសម្រាប់បំភ្លឺពន្លឺតែត្រូវបានលក់នៅក្នុងទីផ្សារសំរាប់ធ្វើជាការចាប់ផ្តើមបង្កាត់ភ្លើងសម្រាប់ចង្រ្កានធ្យូង។ ខ្លះត្រូវបាននាំចេញទៅប្រទេសថៃ។ ដើម្បីប្រមូលជ័រទឹកប្រជាជនជាលើកដំបូងធ្វើការជីករន្ធក្នុងដើមឈើមួយដើម។ បន្ទាប់មកដុតភ្លើងនៅក្នុងរន្ធដើម្បីឱ្យចេញជ័រ ប៉ុន្តែដើមឈើមិនស្លាប់នៅក្នុងដំណើរការនេះទេ។ រៀងរាល់ពីរបីឆ្នាំម្តង អ្នកភូមិនឹងចោះរន្ធមួយនៅកន្លែងផ្សេងគ្នាថ្មីមួយទៀត ហើយរន្ធចាស់គឺមិនត្រូវប្រើទៀតទេដូច្នេះវាដុះពេញឡើងវិញនិងត្រឡប់មករកសភាពដើមដែរ។ ដំណើរការនេះត្រូវបានគ្រប់គ្រងដើម្បីកុំឱ្យដើមឈើនេះងាប់។

ជាប្រពៃណីដើមឪតចឺរូខាភស្វួតមួយដើមនឹងជាកម្មសិទ្ធិរបស់គ្រួសារមួយដែលមានសិទ្ធិក្នុងការយកជ័រពីវា។ ក្នុងគ្រួសារមួយអាចមាន៧ឬ៨ដើមនិងច្រើនបំផុត១០ដើម។ ខណៈពេលដែលវាត្រូវបានអនុញ្ញាតឱ្យយកជ័រ, មិនមានសិទ្ធិកាប់ទេ។ សិទ្ធិក្នុងការយកជ័រត្រូវបានប្រគល់អោយពីជំនាន់មួយទៅជំនាន់មួយ។

## ៣. ខបត្តនៃព្រៃអារក្ស

នៅកណ្តាលប្រទេសឡាវមានព្រៃឈើដែលគេធ្វើសក្ការៈខ្លះបានក្លាយជាតំបន់ព្រៃអភិរក្ស។ ឧទាហរណ៍នៃការភ្ជាប់ជ្រាជ្រៅរវាងជីវិតរស់នៅរបស់មនុស្សនិងព្រៃឈើដូចដែលបានឃើញក្នុងដុនណាថាណុងឡាម(Don NathaNongLam)ជាកន្លែងដែលអ្នកភូមិមានគំរិតក្នុងការប្រមូលអុសដែលជាគំនិតផ្តួចផ្តើមផ្ទាល់របស់គេបង្ហាញពីសក្តានុពលសម្រាប់ការគ្រប់គ្រងធនធានដ៏មានប្រសិទ្ធិភាពដោយអ្នកភូមិខ្លួនឯងផ្ទាល់។

ឥឡូវនេះទោះជាយ៉ាងណាព្រៃឈើដែលត្រូវបានការពារម្តងដោយសេចក្តីស្ញើចរបស់ប្រជាជនជាទីសក្ការៈឥឡូវនេះកំពុងត្រូវបានគំរាមកំហែងដោយការពង្រីកចំការធំៗដូចជាចម្ការកៅស៊ូនិងចម្ការផ្លែឈើក៏

ដូចជាចម្ការអំពៅពីព្រោះសកម្មភាពពាណិជ្ជកម្មទាំងនេះជាញឹកញាប់ទាក់ទងទៅរកការកាប់បំផ្លាញព្រៃឈើធម្មជាតិ។ គួរបញ្ជាក់ផងដែរប្រទេសឡាវមានលក្ខណៈទំនើបខាងរូបនីយកម្មយ៉ាងឆាប់រហ័សដូច្នេះមានតម្រូវការខ្ពស់សម្រាប់អនុផលព្រៃឈើនិងមានការចាប់អារម្មណ៍ដ៏អស្ចារ្យនៅក្នុងដើមជ័រស្ងួតត្រូវអារសំរាប់ធ្វើគ្រឿងផ្ទះ។ តាមគោលនយោបាយមួយរបស់ប្រទេសឡាវគឺត្រូវបានតម្រង់ទិសដើម្បីបង្កើនគម្របព្រៃឈើជាមួយព្រៃឈើពាណិជ្ជកម្ម ប៉ុន្តែក្នុងពេលកន្លងមកមានរបាយការណ៍ជាច្រើនបានពីគម្រោងការដាំដើមឈើឡើងវិញត្រូវបានគេប្រើជាលេសមួយដើម្បីចូលកាប់ព្រៃឈើធម្មជាតិ។ (ណាមូរ៉ា(Namura)ឆ្នាំ ២០០៨អាជ្ញាធរជាតិគ្រប់គ្រងដីឆ្នាំ ២០១០)

ការអភិរក្សព្រៃឈើដ៏មានប្រសិទ្ធិភាពនៅក្នុងអាងទន្លេមេគង្គតម្រូវឱ្យមានមិនត្រឹមតែត្រូវការពិចារណាលើជីវចំរុះនិងសន្តិសុខស្បៀងប៉ុណ្ណោះទេ ប៉ុន្តែអំពាវនាវឱ្យគោរពតម្លៃនៃព្រៃឈើដែលត្រូវបានការពារដោយអ្នកភូមិនិងអារក្ស។ វាជាការសំខាន់ដើម្បីអនុវត្តការគ្រប់គ្រងព្រៃឈើឲ្យសមស្របទៅនឹងតំបន់ដោយមិនគួរផ្តោតលើគោលដៅជាលេខច្រើនពេកនោះទេ។

<u>**ឯកសារយោង:**</u>

Tran, C. T., X. Q. Le, and V. H. Vu. 2007. The Role of Indigenous Knowledge in Sustainable Development: A Case Study of the Vietnam Mountain Regions. In E. K. Boon and L. Hens (eds.) *Tribes and Tribals, Special Volume No. 1 Indigenous Knowledge Systems and Sustainable Development: Relevance for Africa.* Kamla-Raj Enterprises 215-224.

Xu, Jianchu, Erzi T. Ma, DuojieTashi, Yongshou Fu, Zhi Lu, and David Melick. 2005. Integrating Sacred Knowledge for Conservation: Cultures and Landscapes in Southwest China.*Ecology and Society* Vol. 10 Issue 2:7. http://www.ecologyandsociety.org/vol10/iss2/art7/

ឃិគួឈិយូកា